# ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា

## ជំពូក ៥

## សេចក្តីរាយការណ៍ និង ការអង្កេត
## ឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងពេលដោះមីន

---

អគ្គលេខាធិការដ្ឋាន
អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
អគារថ្មីផ្លូវលេខ ២៧៣ កែង ៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ
ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៤១ | ០២៣-៨៨១-៤៩២
គេហទំព័រ: www.cmaa.gov.kh

# មាតិកា


-មាតិកា ........................................................................................................................................ ២

-សេចក្ដីផ្ដើម .................................................................................................................................... ៣

-សេចក្ដីរាយការណ៍ពីសុវត្ថិភាព សុខមាលភាព និង ការអង្កេតឧប្បត្តិហេតុក្នុងពេលដោះមីន............................ ៤

១.ទ្រង់ទ្រាយ .................................................................................................................................. ៤

២.វាក្យស័ព្ទ និង និយមន័យ ................................................................................................................ ៤

៣.របាយការណ៍ឧប្បត្តិហេតុ និងតម្រូវការសម្រាប់ការអង្កេត...................................................................... ៥

៣.១.ឧប្បត្តិហេតុ.............................................................................................................................. ៥

៣.១.១.តម្រូវការទូទៅ........................................................................................................................ ៥

៣.១.២.ទម្រង់របាយការណ៍ ................................................................................................................. ៦

៣.២.ការអង្កេត................................................................................................................................ ៧

៣.២.១.តម្រូវការទូទៅ ....................................................................................................................... ៧

៣.២.២.នីតិវិធីស៊ើបអង្កេត .................................................................................................................. ៧

៣.៣.ការធ្វើរបាយការណ៍ និងការផ្សព្វផ្សាយ ........................................................................................... ៨

៤.ការទទួលខុសត្រូវ.......................................................................................................................... ៨

៤.១.ការទទួលខុសត្រូវរបស់អាជ្ញាធរមីន.................................................................................................. ៨

៤.២.ការទទួលខុសត្រូវរបស់ប្រតិបត្តិករដោះមីន ...................................................................................... ៩

៤.៣.កាតព្វកិច្ចរបស់និយោជិក................................................................................................................ ៩

-ឧបសម្ព័ន្ធ (ជាពត៌មាន) គំរូ នីតិវិធីធ្វើរបាយការណ៍ឧប្បត្តិហេតុដោះមីន.................................................... ១០

-ឧបសម្ព័ន្ធបន្ថែម ក គោលការណ៍ណែនាំដើម្បីជ្រើសរើសកម្រិតស៊ើបអង្កេតមួយដែលសមរម្យ......................... ២១

-ឧបសម្ព័ន្ធ ខ (ជាពត៌មាន) ឧទាហរណ៍ បទដ្ឋានប្រតិបត្តិការ ស៊ើបអង្កេតឧប្បត្តិហេតុដោះមីន ....................... ២៣

-ឧបសម្ព័ន្ធបន្ថែម ខ ឯកសារយោង ..................................................................................................... ២៤

# សេចក្តីផ្តើម

ភាពចាំបាច់ក្នុងការរាយការណ៍ និងការស៊ើបអង្កេតឧប្បត្តិហេតុក្នុងពេលដោះមីនឲ្យបានច្បាស់លាស់ ទូលំទូលាយ និងទាន់ពេលវេលា ជាផ្នែកមួយដ៏សំខាន់នៃការគ្រប់គ្រងសកម្មភាពកំចាត់មីន។

ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការត្រួតពិនិត្យកម្មវិធីកំចាត់មីន និងកាត់បន្ថយគ្រោះថ្នាក់ ដែលអាចនឹងកើតឡើង តែជានិច្ចកាលតែងតែមានឧប្បត្តិហេតុដោះមីនកើតឡើងខានមិនបាន។ មានច្បាប់ និងកាតព្វកិច្ចសម្រាប់អ្នកគ្រប់គ្រងគ្រប់លំដាប់ថ្នាក់នៅក្នុងសកម្មភាពកំចាត់មីន ដើម្បីធានាថាគ្រោះអន្តរាយ ដែលនឹងកើតឡើងត្រូវបានកាត់បន្ថយដល់កម្រិតទាបបំផុត។ ប្រសិទ្ធភាពនៃការធ្វើរបាយការណ៍ និងភាពហ្មត់ចត់នៃការស៊ើបអង្កេតឧប្បត្តិហេតុក្នុងពេលដោះមីន ជាកត្តាសំខាន់មួយ ដើម្បីសម្រេចបានគោលដៅនេះ។ ពត៌មានដែលបានប្រមូល និងបានបង្ហាញនៅក្នុងទម្រង់ច្បាស់លាស់ អាចយកមកប្រើប្រាស់បាន និងជួយផ្តល់ជាបទពិសោធន៍ ឆ្លើយតបទៅនឹងការចាំបាច់បន្ទាន់ ដើម្បីបង្កើនគុណភាពនៃដំណើរការដោះមីន និងកាត់បន្ថយគ្រោះថ្នាក់ ក្នុងប្រតិបត្តិការដោះមីននាពេលអនាគត។

ស្តង់ដានេះ បញ្ជាក់ពីភាពជាក់លាក់ និងការណែនាំពីតម្រូវការជាអប្បបរមា សម្រាប់ធ្វើរបាយការណ៍ និងស៊ើបអង្កេតឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងពេលដោះមីននៅកម្ពុជា។ ស្តង់ដានេះរៀបចំឡើងដោយអនុលោម តាមស្តង់ដាអន្តរជាតិ ស្តីពីការធ្វើរបាយការណ៍ និងការស៊ើបអង្កេតលើឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងពេលដោះមីន។

# សុវត្ថិភាព និងសុខុមាលភាព

## សេចក្តីរាយការណ៍ និង ការស៊ើបអង្កេតឧប្បត្តិហេតុក្នុងពេលដោះមីន

### ១-វិទន់ទ្រាយ

ស្តង់ដានេះ ផ្តល់នូវការណែនាំច្បាស់លាស់ចំពោះអាជ្ញាធរមីន និងអង្គការប្រតិបត្តិដោះមីន នូវតម្រូវការអប្បបរមា សម្រាប់ធ្វើរបាយការណ៍ និងស៊ើបអង្កេតឧប្បត្តិហេតុក្នុងពេលដោះមីន រាប់បញ្ចូលទាំងនិយមន័យសម្រាប់ចាត់ជាប្រភេទនៃឧប្បត្តិហេតុ ដែលនឹងផ្តល់នូវបទពិសោធន៍ និងជាផលប្រយោជន៍ សម្រាប់សហគមន៍កំចាត់មីនទាំងមូល។

ស្តង់ដានេះ ប្រើសម្រាប់តែធ្វើរបាយការណ៍ និងស៊ើបអង្កេតឧប្បត្តិហេតុ ដែលកើតឡើងនៅកន្លែងដោះមីន ប៉ុណ្ណោះ មិនសម្រាប់ឧប្បត្តិហេតុ ដែលកើតនៅឆ្ងាយពីកន្លែងដោះមីននោះទេ។

### ២-វាក្យស័ព្ទ និងនិយមន័យ

សទ្ទានុក្រមនៃវាក្យស័ព្ទ និងនិយមន័យទាំងអស់ ដែលប្រើនៅក្នុងស្តង់ដានេះ នឹងមានចងក្រងនៅពេលខាងមុខ។

**-គ្រោះថ្នាក់**

ជាហេតុការណ៍ដែលនាំឲ្យអន្តរាយដោយមិនបានប៉ងប្រាថ្នា។

**-ការដោះមីន**

គឺជាសកម្មភាពទាំងឡាយ ដែលនាំដល់ការយកគ្រាប់មីន និងគ្រាប់UXO ចេញពីតំបន់មានមីនរាប់បញ្ចូលទាំងការស្រាវជ្រាវបច្ចេកទេស ការគូសផែនទីបោសសម្អាតមីន បោះផ្លាកសញ្ញា ការរៀបចំឯកសារក្រោយពេលដោះមីន ការសម្របសម្រួលក្នុងសហគមន៍ និងការប្រគល់ជាផ្លូវការនូវដីដែលដោះមីនរួច។ ការដោះមីន អាចប្រព្រឹត្តទៅតាមរូបភាពផ្សេងៗនៃអង្គការប្រតិបត្តិនីមួយៗ ដូចជា អង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនពាណិជ្ជកម្ម ក្រុមសកម្មភាពកំចាត់មីនជាតិ ឬផ្នែកយោធាជាដើម។ ការដោះមីន គឺសំដៅលើភាពបន្ទាន់ចាំបាច់ និងសម្រាប់កិច្ចអភិវឌ្ឍន៍។

**-គ្រោះថ្នាក់ដោយសារដោះមីន**

សំដៅលើគ្រោះថ្នាក់ដែលកើតឡើងនៅការដ្ឋានដោះមីន ដែលមានមីន និងគ្រាប់មិនទាន់ផ្ទុះ។

ក. គ្រោះថ្នាក់ក្នុងពេលដោះមីន។

**-ឧប្បត្តិហេតុដោយសារដោះមីន**

ជាឧប្បត្តិហេតុដែលកើតឡើងដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ នៅកន្លែងបោសសម្អាតមីន

( ឧប្បត្តិហេតុដោយសារមីន )

**-ឧប្បត្តិហេតុ**

ជាព្រឹត្តិការណ៍មួយ ដែលនាំទៅដល់គ្រោះថ្នាក់ ឬមានអានុភាពអ្វីមួយដែលបណ្តាលឲ្យគ្រោះថ្នាក់ (ILOC155)

**-គ្រោះថ្នាក់ដោយសារមីន**

ជាគ្រោះថ្នាក់ដែលមិនកើតនៅចម្ការដែលមានមីន និងគ្រាប់មិនទាន់ផ្ទុះទេ។

**-ឧប្បត្តិហេតុដោយសារមីន**

ជាឧប្បត្តិហេតុដែលកើតមានក្រៅពីកន្លែងដោះមីន ដែលពាក់ព័ន្ធនឹងតំបន់គ្រោះថ្នាក់មីន ឬយុទ្ធ ភ័ណ្ឌមិនទាន់ផ្ទុះ ( ឧប្បត្តិហេតុដោះមីន )។

## ៣. របាយការណ៍ឧប្បត្តិហេតុ និងតម្រូវការនានាសម្រាប់ការស៊ើបអង្កេត

### ៣.១.ឧប្បត្តិហេតុ

### ៣.១.១. តម្រូវការទូទៅ

ត្រូវរាយការណ៍ជូនអាជ្ញាធរមីនជាបន្ទាន់ចំពោះឧប្បត្តិហេតុដូចខាងក្រោមៈ

ក). គ្រោះថ្នាក់ដែលបង្កឡើងដោយគ្រាប់មីន គ្រាប់មិនទាន់ផ្ទុះ ចំពោះអ្នកណាម្នាក់នៅការដ្ឋានដោះមីន។

ខ). ឧប្បត្តិហេតុដែលបង្កឡើងដោយគ្រាប់មីន ឬគ្រាប់មិនទាន់ផ្ទុះ បណ្តាលឲ្យខូចខាតសម្ភារៈទ្រព្យសម្បត្តិនៅកន្លែងដោះមីន។

គ). ការរកឃើញគ្រាប់មីន ឬគ្រាប់មិនទាន់ផ្ទុះ នៅក្នុងតំបន់ដែលបានបោសសម្អាតមីនរួច ឬដាក់សញ្ញាសម្គាល់ថាបានបោសសម្អាតមីនរួច ទោះជាមានឬគ្មានគ្រោះថ្នាក់ដោយសារមីន/គ្រាប់មិនទាន់ផ្ទុះ ដែលនៅសល់នោះក៏ដោយ។

ឃ). នៅពេលដែលមាននរណាម្នាក់ សម្តែងឲ្យឃើញពីគ្រោះថ្នាក់ ដែលនឹងអាចកើតមានឡើង ដោយសារការប្រើប្រាស់ស្តង់ដា ឬបទដ្ឋានប្រតិបត្តិការ រាប់បញ្ចូលទាំងការខកខានបើកសម្ភារៈឲ្យនិយោជិកផង។

ង). ការផ្ទុះមីន ឬគ្រាប់មិនទាន់ផ្ទុះនៅក្រៅគម្រោងផែនការ នៅឯការដ្ឋានដោះមីន ដោយមិនគិតពីមូលហេតុ ឬលទ្ធផលឡើយ។ នៅពេលអាជ្ញធរមីន បានទទួលរបាយការណ៍ឧប្បត្តិហេតុដែលបញ្ជាក់ពីចំណុចខ្វះខាតនៃសម្ភារៈ ស្តង់ដា បទដ្ឋានប្រតិបត្តិការ ឬក៏បង្ហាញឲ្យឃើញពីគ្រោះថ្នាក់បែបផ្សេង អាជ្ញាធរមីននឹងផ្សព្វផ្សាយបម្រាមជាទូទៅមួយ ចំពោះអង្គការសកម្មភាពកំចាត់មីនទាំងអស់ ដែលប្រើប្រាស់សម្ភារៈ ស្តង់ដា ឬបទដ្ឋានប្រតិបត្តិការដូចគ្នា។

### ៣.១.២.ទម្រង់បែបបទសម្រាប់ធ្វើរបាយការណ៍

របាយការណ៍ឧប្បត្តិហេតុដោះមីន ត្រូវដាក់បញ្ចូលពត៌មានជាអប្បបរមាដូចខាងក្រោមៈ

ក). ប្រតិបត្តិករដោះមីន និងអង្គភាពចំណុះ (មានឈ្មោះអ្វីក៏ដោយ ឬអាចសម្គាល់បាន)

ខ). ទីតាំងនៃឧប្បត្តិហេតុ រាប់បញ្ចូលទាំងលេខកំណត់សម្គាល់តំបន់គ្រោះថ្នាក់ ឬលេខយោង។

គ). សភាពពិតនៃឧប្បត្តិហេតុ (ឧទាហរណ៍: នៅសល់មីន គ្រោះថ្នាក់ដោយសារដោះមីន ឬសង្ស័យថាមានកង្វះខាតឯកសារស្តង់ដា ឬបទដ្ឋានប្រតិបត្តិការមានលក្ខណៈខ្វះខាត ឬសង្ស័យថាអនុវត្តប្រាស់ចាកពីបទដ្ឋានប្រតិបត្តិការ)។

ឃ). ប្រភេទនៃគ្រាប់រំសេវ (បើដឹង)។

ង). ឧប្បត្តិហេតុបណ្តាលឲ្យអន្តរាយ (របួស ឬស្លាប់អ្នកដោះមីន អ្នកត្រួតពិនិត្យ ភ្ញៀវ ឬសមាជិកនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន)។

ច). ឧប្បត្តិហេតុបណ្តាលឲ្យខូចខាត (ឧទាហរណ៍: សម្ភារៈ ឃ្លាំង ឧបករណ៍ការពារខ្លួន ឬទ្រព្យសម្បត្តិ)។

ឆ). ពិពណ៌នាអំពីហេតុការណ៍ដែលនាំឲ្យកើតឧប្បត្តិហេតុ។

ជ). ឈ្មោះ និងអាស្រ័យដ្ឋានទាក់ទងរបស់សាក្សី ឬអ្នកដែលអាចជួយក្នុងការស៊ើបអង្កេតនៃឧបត្តិហេតុនោះ។

ឈ). ពិពណ៌នាអំពីសកម្មភាព ដែលបានអនុវត្តដើម្បីសង្គ្រោះជនរងគ្រោះជាបន្ទាន់ ឧទាហរណ៍នៃរបាយការណ៍ឧប្បត្តិហេតុមាននៅក្នុងឧបសម្ព័ន្ធ ក ។

### ៣.២.ការស៊ើបអង្កេត

#### ៣.២.១.តម្រូវការទូទៅ

អាជ្ញាធរមីននឹងធ្វើការតែងតាំងបុគ្គលិកដែលមានលក្ខណៈសម្បត្តិសមរម្យ និងបទពិសោធន៍ ដើម្បីធ្វើការស៊ើបអង្កេតឧប្បត្តិហេតុ ដូចខាងក្រោម:

ក). ឧប្បត្តិហេតុក្នុងពេលដោះមីន ដែលបណ្តាលមកពីការប្រើប្រាស់ស្តង់ដា ឬនីតិវិធីដែលបានអនុម័តរួច។

ខ). គ្រោះថ្នាក់មីន ឬយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែលកើតមានជាយថាហេតុ នៅក្នុងកន្លែងដោះមីន

គ). ភាពអន្តរាយ ដែលបណ្តាលមកពីគ្រោះថ្នាក់ក្នុងពេលដោះមីន។

ឃ). ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិ។

ង). ការខូចខាត ដែលបណ្តាលឲ្យមានការប្តឹងទារជម្ងឺចិត្តពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

#### ៣.២.២. នីតិវិធីស៊ើបអង្កេត

គោលបំណងនៃការស៊ើបអង្កេតឧប្បត្តិហេតុក្នុងពេលដោះមីន គឺដើម្បីរកឲ្យឃើញនូវបញ្ហា ឬឱកាស ដើម្បីបង្កើនសុវត្ថិភាព និងគុណភាពនៃកិច្ចប្រតិបត្តិការបោសសម្អាតមីន មិនមែនជាការស៊ើបអង្កេតបទឧក្រិដ្ឋ ឬវាយ តម្លៃការប្តឹងសងថ្លៃជានារាប់រងនាពេលបច្ចុប្បន្ន ឬអនាគតឡើយ។ ដូចនេះ បុគ្គលិកនៃប្រតិបត្តិករដោះមីនទាំង អស់ត្រូវផ្តល់ព័ត៌មានឲ្យបានពេញលេញ និងត្រឹមត្រូវអំពីព្រឹត្តិការណ៍ជុំវិញឧប្បត្តិហេតុ និងផ្តល់យោបល់ រិះរកនីតិវិធីឲ្យរឹតតែប្រសើរឡើង ដើម្បីទប់ស្កាត់កុំឲ្យឧប្បត្តិហេតុកើតឡើងទៀត។

នៅពេលចាប់ផ្តើមស៊ើបអង្កេតឧប្បត្តិហេតុក្នុងពេលដោះមីន អាជ្ញាធរមីនត្រូវធានាថា:

ក). ការស៊ើបអង្កេតត្រូវចាប់ផ្តើមអនុវត្តឲ្យបានឆាប់បំផុត។

ខ). មន្ត្រីស៊ើបអង្កេត ឬក្រុមស៊ើបអង្កេតរបស់អាជ្ញាធរមីន ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងបទពិសោធន៍ជំនាញដែលចាំបាច់ ដើម្បីឆ្លើយតបនឹងតម្រូវការសម្រាប់ការស៊ើបអង្កេត។

គ). មន្ត្រីស៊ើបអង្កេត ត្រូវមានឯករាជ្យភាព និងមិនមានជាប់ពាក់ព័ន្ធជាមួយប្រតិបត្តិករដោះ មីន ដែលជួបនឹងឧប្បត្តិហេតុ។

ឃ). អាជ្ញាធរមីន នឹងផ្តល់ឯកសារយោងសម្រាប់ការស៊ើបអង្កេតមួយច្បាប់ដល់ប្រតិបត្តិករដោះ មីន ដើម្បីជាជំនួយក្នុងការសួរនាំពេលចុះអង្កេត។

ង). របាយការណ៍ស៊ើបអង្កេត ត្រូវដាក់ជូនអាជ្ញាធរមីនឲ្យទាន់ពេលវេលា និងបំពេញឲ្យបាន គ្រប់លក្ខណៈងាយយល់ សង្ខេបខ្លី និងត្រឹមត្រូវ (ត្រូវមានទាំងសេចក្តីសន្និដ្ឋាន និងអនុសាសន៍ ដែលធ្វើឲ្យប្រសើរឡើងផង) លើកលែងតែកាលៈទេសៈមិនអំណោយផល។

ប្រតិបត្តិករដោះមីន ដែលពាក់ព័ន្ធនៅក្នុងឧប្បត្តិហេតុត្រូវធានាថា:

ច). របាយការណ៍ពីឧប្បត្តិហេតុ នឹងត្រូវផ្តល់ជូនអាជ្ញាធរមីនជាបន្ទាន់តាមតែអាចធ្វើបាន។

ឆ). កន្លែងកើតឧប្បត្តិហេតុ ត្រូវរក្សាទុកភាពដើមរហូតដល់មន្ត្រី ឬក្រុមស៊ើបអង្កេតអនុញ្ញាត ដើម្បីរក្សាព័ត៌មានដែលមានសារៈប្រយោជន៍។

ជ). ធ្វើការថតរូបភាពភ្លាមៗពីកន្លែងកើតឧប្បត្តិហេតុ។

ឧទាហរណ៍នៃបទដ្ឋានប្រតិបត្តិការស៊ើបអង្កេត មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ខ

### ៣.៣. ការធ្វើរបាយការណ៍ និងការផ្សព្វផ្សាយ

ត្រូវធ្វើការចែកផ្សព្វផ្សាយឲ្យបានទូលាយនូវព័ត៌មានដូចខាងក្រោមនេះ:

ក). ព្រឹត្តិការណ៍ដែលនាំឲ្យអន្តរាយបណ្តាលមកពីឧប្បត្តិហេតុ។

ខ). ការវិភាគព័ត៌មានដែលប្រមូលបានក្នុងអំឡុងពេលធ្វើការស៊ើបអង្កេត។

គ). លទ្ធផលនៃការស៊ើបអង្កេត (ការសន្និដ្ឋាន និងអនុសាសន៍បានពីការស៊ើបអង្កេត) អាជ្ញាធរមីន ត្រូវផ្សព្វផ្សាយព័ត៌មានស្តីពីឧប្បត្តិហេតុក្នុងពេលដោះមីននេះ។

## ៤. ភារទទួលខុសត្រូវ

### ៤.១.ការទទួលខុសត្រូវរបស់អាជ្ញាធរមីន

អាជ្ញាធរមីនត្រូវ:

ក). ថែទាំ និងកែសម្រួលនីតិវិធីទៅតាមតម្រូវការសម្រាប់ធ្វើរបាយការណ៍ និងស៊ើបអង្កេតឧប្បត្តិហេតុ ដូចដែលបានអត្ថាធិប្បាយនៅក្នុងស្តង់ដានេះ។

ខ). តែងតាំងក្រុមស៊ើបអង្កេតមួយ។

គ). ផ្សព្វផ្សាយលទ្ធផលនៃរបាយការណ៍ស៊ើបអង្កេត ដល់ប្រតិបត្តិករដោះមីនទាំងអស់ ដែលកំពុងប្រតិបត្តិការនៅកម្ពុជា។

ឃ). ផ្សព្វផ្សាយលទ្ធផលនៃរបាយការណ៍ស៊ើបអង្កេត ដល់អង្គការសហប្រជាជាតិ ផ្នែកសេវាកម្មកំចាត់មីន។

ង). ជានាថា លទ្ធផលនៃរបាយការណ៍ពិនិត្យសុខភាព របាយការណ៍ក្រោយពេលមរណភាព របាយការណ៍កោសល្យវិច័យ ត្រូវបានចែកដល់អ្នកគ្រប់គ្រងប្រតិបត្តិករដោះមីន។

**៤.២. ការទទួលខុសត្រូវរបស់ប្រតិបត្តិករដោះមីនៈ**

ប្រតិបត្តិករដោះមីនត្រូវៈ

ក). រាយការណ៍ជូនអជ្ញាធរមីនជាបន្ទាន់ តាមតែអាចធ្វើបានពីឧប្បត្តិហេតុដោះមីន។

ខ). ថតរូបភាពកន្លែងកើតឧប្បត្តិហេតុដោះមីនជាបន្ទាន់ រក្សាទុកភាពដើម ដើម្បីរង់ចាំការធ្វើអធិការកិច្ច និងបទបញ្ជាពីក្រុមស៊ើបអង្កេតរបស់អាជ្ញាធរមីន។

គ). បើកទូលាយឲ្យចេញចូល និងផ្គត់ផ្គង់ផ្នែករដ្ឋបាលដល់ក្រុមស៊ើបអង្កេតឧប្បត្តិហេតុ បើសិនជាចាំបាច់។

ឃ). ត្រូវផ្តល់ឲ្យក្រុមស៊ើបអង្កេតនូវប្លង់ការដ្ឋាន បទដ្ឋានប្រតិបត្តិការ របាយការណ៍ហ្វឹកហ្វឺនសៀវភៅកត់ត្រាអំពីការប្រើប្រាស់វិទ្យុទាក់ទង ច្បាប់ដើមឯកសារផ្សេងៗទៀត ឬសម្ភារៈដែលទាក់ទងផ្ទាល់ទៅនឹងការស៊ើបអង្កេតគ្រោះថ្នាក់នោះ។

ង). ជួយដល់បុគ្គលិក ដែលត្រូវបានតែងតាំងឲ្យចុះស៊ើបអង្កេតឧប្បត្តិហេតុ ក្នុងកិច្ចប្រតិបត្តិការមីននោះ។

**៤.៣. កាតព្វកិច្ចរបស់និយោជិក**

អ្នកដោះមីនត្រូវៈ

ក). អនុវត្តឲ្យបានខ្ជាប់ខ្ជួននូវស្តង់ដា និងបទដ្ឋានប្រតិបត្តិការដែលរៀបចំឡើង ដើម្បីការពារកុំឲ្យមានឧប្បត្តិហេតុកើតឡើង។

ខ). រាយការណ៍ពីចំណុចខ្សោយរបស់សម្ភារៈ និងនីតិវិធី។

គ). រាយការណ៍ពីឧប្បត្តិហេតុណាដែលគួររាយការណ៍។

ឃ). ជួយដល់ការស៊ើបអង្កេតឧប្បត្តិហេតុ។

# ឧបសម្ព័ន្ធ ក (ជាព័ត៌មាន)

## ឧទាហរណ៍ និតិវិធីធ្វើរបាយការណ៍ឧប្បទ្ទវហេតុដោះមីន

| | | | |
|---|---|---|---|
| **ចំណងជើង:** របាយការណ៍ឧប្បទ្ទវហេតុដោះមីន | លេខ: | កាលបរិច្ឆេទ: | |
| **បំណង:** ធ្វើរបាយការណ៍ឧប្បទ្ទវហេតុដោះមីនឲ្យបានសុក្រឹត និងមានប្រសិទ្ធិភាព ដើម្បីជាជំនួយក្នុងការឆ្លើយតបជាបន្ទាន់ និងចាប់ផ្តើមការស៊ើបអង្កេត។ | អ្នកប្រើប្រាស់:<br>អ្នកគ្រប់គ្រង: | | |
| ការពិពណ៌នា | ការទទួលខុសត្រូវ | | |
| | ប្រធានការដ្ឋាន | ប្រតិបត្តិករដោះមីន | អាជ្ញាធរមីន |
| **ឧប្បទ្ទវហេតុដោះមីន:**<br>អនុវត្តនិតិវិធីប្រតិបត្តិការឆ្លើយតបជាបន្ទាន់និងនិតិវិធីប្រតិបត្តិការការពារកន្លែងឧប្បទ្ទ | | | |
| **ការប្រមូលទិន្នន័យ និងរៀបចំធ្វើរបាយការណ៍:** រាប់បញ្ចូលទាំងរូបថត បញ្ជីឈ្មោះសាក្សី សំភារៈ បច្ចេកវិទ្យាមានកំហុស | | | |
| **ដាក់ជូនរបាយការណ៍ជំហានដំបូង:**<br>ជូនរបាយការណ៍ជំហានដំបូងតាមមធ្យោបាយដែល លឿនបំផុត | | | (1) |
| **កំណត់សំគាល់ឧប្បទ្ទវហេតុជាគ្រោះថ្នាក់ដែលមិនអាចទទួលយកបាន**<br>ក.តើមាននៅក្នុងស្តង់ដាឬនិតិវិធីប្រតិបត្តិការដែលមានការឯកភាពឬទេ?<br>ខ.តើជាគ្រោះថ្នាក់ដែលមិនអាចដឹងមុន(ឧបករណ៍ថ្មី | | | បាទ |
| **ផ្ញើសារព្រមានជាទូទៅ:** សារព្រមានជាទូទៅ ត្រូវតែណែនាំអោយប្រុងប្រយ័ត្នពីការប្រើប្រាស់ស្តង់ដានិតិវិធីប្រតិបត្តិការ បច្ចេកវិទ្យា ឬគ្រោះថ្នាក់មិនអាចដឹងមុន(ឧបករណ៍ថ្មី បច្ចេកទេសដាក់មីន ឬដាក់អន្ទាក់)។ | | | ទេ |
| **តើត្រូវការស៊ើបអង្កេតជាផ្លូវការឬទេ?** សូមអានឧបសម្ព័ន្ធបន្ថែម ក ទៅ ដល់ យ ណែនាំអង្គការសកម្មភាពកំចាត់មីនអោយដាក់ជូនរបាយការណ៍លំអិត។ | | | ទេ |
| **ដាក់ជូនរបាយការណ៍លំអិត:** ចងក្រង និងដាក់ជូនរបាយការណ៍លំអិត | | | បាទ |
| **តែងតាំងគណៈកម្មាការ ឬមន្ត្រីស៊ើបអង្កេត** | | | |
| **ស៊ើបអង្កេតឧប្បទ្ទវហេតុ:** អង្គការសកម្មភាពកំចាត់មីនត្រូវជួយដល់ក្រុមស៊ើបអង្កេត។ | | | |
| **ដាក់របាយការណ៍ជូនសមត្ថកិច្ចប៉ូលីស ឬអាជ្ញាធរជាតិផ្សេងៗទៀតតាមតម្រូវការ** | | | |

ឯកសារ ដំណើរការ ការទទួលខុសត្រូវទ្វេ ឯកសារច្រើន ការសំរេច អ្នកតភ្ជាប់

**មកពី** : ប្រតិបត្តិករដោះមីន នៅកម្ពុជា (សូមអានចំណាំទី ១ និងចំណាំទី ២)

**សូមគោរពជូន**

**ឯកឧត្តមអគ្គលេខាធិការ**

**អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន**

អាស័យដ្ឋានលេខ ២៧៤ មហាវិថីសហពន្ធ័រុស្ស៊ី, ភ្នំពេញ

ទូរស័ព្ទលេខ:.......................... ទូរសារលេខ:...................................................

**កាលបរិច្ឆេទ និង ពេលវេលា:** (សូមអានចំណាំទី ៣)

**កម្មវត្ថុ:** របាយការណ៍ជនរងគ្រោះដោយសារមីន / ការខូចខាតសម្ភារៈ

១. អង្គការ, ការិយាល័យ, គម្រោងកម្មវិធីលេខ, ឈ្មោះក្រុម, លេខក្រុម:
២. ទីតាំង (ខេត្ត, ស្រុក, ភូមិ ភារកិច្ចលេខ):
៣. កាលបរិច្ឆេទ និងពេលវេលានៃឧប្បត្តិហេតុ:
៤. ឈ្មោះអ្នករងរបួស (សូមអានចំណាំ៤)
 ក. ការពិពណ៌នាពីរបួស (សូមអានចំណាំទី ៥)
 ខ. ការព្យាបាល
 គ. សភាពរបស់ជនរងគ្រោះពេលបច្ចុប្បន្ន
៥. ផ្លូវ និង គោលដៅដែលត្រូវជម្លៀសជនរងគ្រោះ ៖
៦. ធ្វើបញ្ជីសម្ភារៈ មធ្យោបាយដែលបានខូចខាត (សូមអានចំណាំទី ៦)
៧. ពិពណ៌នា ថាតើឧប្បត្តិហេតុកើតឡើងដោយរបៀបណា (សូមអានចំណាំទី ៧)
៨. ព័ត៌មានផ្សេងៗទៀត (សូមអានចំណាំទី ៨)
 ក. តើឧប្បត្តិហេតុកើតឡើងនៅក្នុងតំបន់បោសសម្អាតមីនរួច តំបន់សុវត្ថិភាព ឬ តំបន់ដែលមានមីន?
 ខ. ប្រភេទនៃគ្រឿងផ្ទុះ (បើស្គាល់)
៩. ពត៌មានផ្សេងៗ (សូមអានចំណាំទី៩)

**កំណត់ចំណាំ:**

១.ផ្តល់អាស័យដ្ឋានច្បាស់លាស់របស់អ្នកទទួលខុសត្រូវក្នុងការសម្របសម្រួល ដើម្បីឆ្លើយតបជាបន្ទាន់ចំពោះឧប្បត្តិហេតុដោះមីន និងសម្រួលសកម្មភាពស៊ើបអង្កេត។ ឧទាហរណ៍: ប្រធានប្រតិបត្តិការ (សញ្ញាហៅ លេខទូរស័ព្ទ)។

២.ព័ត៌មាន ដែលបានដាក់ពណ៌ប្រផេះនេះ ត្រូវរាយការណ៍តាមនីតិវិធីវិទ្យុទាក់ទង ឬតាមទូរស័ព្ទ ឲ្យបានឆាប់បំផុត ព័ត៌មានលំអិតត្រូវរាយការណ៍តាមទូរសារ ឬអ៊ីម៉េល។ ព័ត៌មាន ដែលបញ្ជូនតាមទូរសារ ឬ អ៊ីម៉េលនោះត្រូវទូរស័ព្ទប្រាប់ឲ្យដឹងផង។

៣.កាលបរិច្ឆេទ និងពេលវេលាដាក់របាយការណ៍ជូន (ចំណុចនេះត្រូវបានគេប្រើដើម្បីជួយតាមដានប្រព័ន្ធរបាយការណ៍ និងជួយរកវិធីបង្កើនប្រព័ន្ធរបាយការណ៍ឲ្យរឹតតែប្រសើរថែមទៀត)

៤.ចំពោះអ្នកដោះមីន ត្រូវដាក់បញ្ចូលទាំងមុខងារនៃការងារ (អ្នកបោសសម្អាតមីន ប្រធានក្រុមអ្នកស្រាវជ្រាវ ពេទ្យ អ្នកបើកបរ)។ល។ ចំពោះអ្នកដទៃទៀត ត្រូវបញ្ចូលអាស័យដ្ឋាន ទំនាក់ទំនងរបស់ជនរងគ្រោះផង។

៥.ធ្វើបញ្ជីនៃការរងរបួសសម្រាប់មនុស្សម្នាក់ៗ ដាច់ដោយឡែកពីគ្នា

៦.ធ្វើបញ្ជីសម្ភារៈ ឬមធ្យោបាយ ដែលរងការខូចខាតដោយពណ៌នាខ្លីៗ អំពីទំហំនៃការខូចខាត ឈ្មោះសម្ភារៈ និងអាស័យដ្ឋានទាក់ទងដល់ម្ចាស់សម្ភារៈនីមួយៗ។

៧.ត្រូវដាក់បញ្ចូលការពណ៌នាយ៉ាងខ្លីមួយនៃឧប្បត្តិហេតុ ឧទាហរណ៍: "ឧប្បត្តិហេតុកើតឡើង នៅពេលកំពុងអនុវត្តក្បួនចាក់រកមីន PMN។ គ្រាប់មីននេះ ស្ថិតនៅក្នុងតំបន់មួយដែលគ្របដណ្តប់ដោយព្រៃឫស្សី។ អ្នកបោសសម្អាតមីនជួបការលំបាកក្នុងការកាត់ និងយកឫសឫស្សីចេញ ដែលជាហេតុនាំឲ្យមីននោះផ្ទុះឡើងតែម្តង"។

៨.ក្នុងករណីកើតឧប្បត្តិហេតុដោយសារមីនដែលនៅសល់ពីការបោសសម្អាត ត្រូវដាក់បញ្ចូលព័ត៌មានលំអិតថា តើមីនដែលនៅសល់នោះបានរកឃើញដោយរបៀបណា។ ឧទាហរណ៍: មីន ត្រូវបានរាយការណ៍បន្ទាប់ពីការដោះមីន មីនរកឃើញក្នុងពេលជ្រើសរើសដីយកធ្វើគំរូ ឬនៅក្នុងផ្លូវសុវត្ថិភាព ដែលបានបោសសម្អាតដោយក្រុមស្រាវជ្រាវ។

៩.ត្រូវផ្តល់ព័ត៌មានឲ្យបានច្រើនបំផុត ពីហេតុការណ៍ជុំវិញឧប្បត្តិហេតុ។ ឧទាហរណ៍: ព័ត៌មាន ដែលអាចជួយដល់ការសម្រេចចិត្ត ដើម្បីផ្សព្វផ្សាយការព្រមានជាទូទៅពីប្រភេទគ្រឿងផ្ទុះ ដែលបានរកឃើញ ការខ្វះចន្លោះនៃស្តង់ដា ឬបទដ្ឋានប្រតិបត្តិការ។ របាយការណ៍ ត្រូវដាក់ជូនឲ្យបានឆាប់បំផុត ដើម្បីប្រមូល និងវិភាគព័ត៌មានដែលទាក់ទងនឹងឧប្បត្តិហេតុ។

**ឧប្បត្តិហេតុដោះមីន - របាយការណ៍លំអិត**

**ផ្នែកទី១: ការពិពណ៌នាអំពីឧប្បត្តិហេតុ**

១.ឈ្មោះ ប្រតិបត្តិករដោះមីន ..............................................ក្រុមលេខ..................................................

២.កាលបរិច្ឆេទនៃឧប្បត្តិហេតុ............../...................../......................ម៉ោង............................................

៣.ទីតាំងនៃឧប្បត្តិហេតុ: ខេត្ត.........................ស្រុក.......................ឃុំ.......................ភូមិ........................

គម្រោងកម្មវិធី ឬភារកិច្ចលេខ.................................................................................................................. ។

៤. ឈ្មោះប្រធានការដ្ឋាន ឬ ប្រធានក្រុម

៥. ប្រភេទនៃឧប្បត្តិហេតុ: ការផ្ទុះមីន/គ្រាប់យុទ្ធភ័ណ្ឌដែលនៅសល់ ☐

៦. គ្រឿងផ្ទុះបានធ្វើឲ្យផ្ទុះដោយ:

អ្នកដោះមីន/អ្នកស្រាវជ្រាវ☐ ឆ្កែហិតរកមីន☐ មេក្រុម☐ រថយន្ត☐ ផ្សេងៗ☐ (បញ្ជាក់)

មិនដឹង ☐ (ឆ្លងទៅទី ៧ )

៦.ក. គ្រឿងផ្ទុះបានផ្ទុះឡើងក្នុងពេលកំពុង:

ប្រើម៉ាស៊ីន☐ ចាក់/កាយដីចេញ☐ រៀបចំកំទេចយកចេញ☐ ផ្សេងៗ☐ (បញ្ជាក់)

៧. គ្រឿងផ្ទុះត្រូវបានរកឃើញនៅក្នុងតំបន់ដែលបានបែងចែកដូចខាងក្រោម:

តំបន់ប្រើការបាន☐ តំបន់ដែលដឹងថាមានគ្រោះថ្នាក់☐ តំបន់មិនស្គាល់☐ (ឆ្លងទៅទី៧)

តំបន់បោសសម្អាតមីនរួច☐ (ឆ្លងទៅទី ៦ក)

៧.ក. ផ្តល់ព័ត៌មានច្បាស់លាស់ពីទីតាំងឧប្បត្តិហេតុ និងឈ្មោះរបស់ប្រតិបត្តិករដោះមីន បើដឹង

៨. អត្ថាធិប្បាយ (ពណ៌នាថា តើឧប្បត្តិហេតុកើតឡើងដោយរបៀបណា។ សូមភ្ជាប់មកជាមួយនូវ ទំព័របន្ថែម និងរូបថត ឬដ្យាក្រាមដើម្បីជួយបញ្ជាក់ពីហេតុការណ៍ជុំវិញឧប្បត្តិហេតុនេះ):

**ផ្នែកទី២: របួស**

៩. តើឧប្បត្តិហេតុនោះបណ្តាលឲ្យមានរបួសស្នាមដែរឬទេ? មាន☐ គ្មាន☐ (ឆ្លងទៅទី ១០)

៩.ក.ធ្វើបញ្ជីឈ្មោះអ្នករងរបួស និងសភាពនៃរបួស

ឈ្មោះ.................................... មុខងារ.................................. របួស............សកម្មភាព..........................

៩.ខ. គឺសំដៅទៅលើសកម្មភាពដែលបានកំពុងប្រព្រឹត្ត ចំពេលឧប្បត្តិហេតុកើតឡើង។ ឧទាហរណ៍ ត្រួតពិនិត្យ អ្នកដោះមីន ចាក់រកមីន ប្រើម៉ាស៊ីន បញ្ជាឆ្កែឲ្យហិតរកមីននៅក្រោមអគារ។ល។

៩-គ-សូមភ្ជាប់ជាមួយនូវសន្លឹកទិន្នន័យសម្រាប់អ្នករងរបួសម្នាក់ៗ (សូមអានឯកសារភ្ជាប់ទីមួយ)

**ផ្នែកទី៣: ការខូចខាតសម្ភារៈ**

១០. តើឧប្បត្តិហេតុនេះបណ្តាលឲ្យខូចខាតសម្ភារៈ ឬទ្រព្យសម្បត្តិដែរឬទេ?

បាទ, ចាស☐ ទេ☐ (ឆ្លងទៅទី ១៣)

១១. ធ្វើបញ្ជីសម្ភារៈដោះមីន ឬទ្រព្យសម្បត្តិដែលខូចខាត ឈ្មោះសម្ភារៈ (និងលេខលំដាប់) ការខូចខាត

១២. ធ្វើបញ្ជីនៃការខូចខាតចំពោះសម្ភារៈ ឬទ្រព្យសម្បត្តិដែលមានម្ចាស់ជាសមាជិករដ្ឋការរដ្ឋាភិបាល ។

ត្រូវដាក់បញ្ចូលទាំងអាស័យដ្ឋានទាក់ទងរបស់ម្ចាស់ សម្ភារៈ ឬអ្នកទទួលខុសត្រូវផង ។

ឈ្មោះសម្ភារៈ............................................................ការខូចខាត..................................

**ផ្នែកទី៤: គ្រោះថ្នាក់រំសេវផ្ទុះ**

១៣. សូមផ្តល់ព័ត៌មានលំអិតអំពីមីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ/គ្រឿងផ្ទុះផ្សេងទៀត ដែលពាក់ព័ន្ធក្នុងឧប្បត្តិហេតុ។

| ប្រភេទនៃគ្រឿងផ្ទុះ: | វិធី: | កំណត់ដោយ: |
|---|---|---|
| មីនប្រឆាំងថ្មើរជើង(អម្បែង)☐ | ដាក់កប់ដី ☐ | ពិនិត្យមើល ☐ |
| មីនប្រឆាំងថ្មើរជើង(ខ្យល់) ☐ | ដាក់លើដី ☐ | រកឃើញអម្បែង☐ |
| មីនប្រឆាំងរថក្រោះ ☐ | ដាក់ជាខ្សែទាក់ ☐ | សង្ស័យ ☐ |
| យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ☐ | ដាក់ច្នៃជាអន្ទាក់☐ | អន្ទាក់ ☐ |
| មិនដឹង ☐ | មិនដឹង ☐ | |

១៤. បញ្ជាក់គ្រឿងផ្ទុះឲ្យបានច្បាស់លាស់ (បើដឹង)

-ប្រភេទចំនួនកំណាត់សម្គាល់ (រួមទាំងប្រភេទមីន)

-មីនប្រឆាំងថ្មើរជើង

-មីនប្រឆាំងរថក្រោះ

-យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

១៥. ការផ្តល់យោបល់ (រាប់បញ្ចូលទាំងការវាស់វែងទំហំរណ្តៅ ដែលបណ្តាលមកពីការផ្ទុះ)

**ផ្នែកទី៥: ស្ថានភាពការដ្ឋាន**

១៦. ពណ៌នាពីស្ថានភាពនៅការដ្ឋាននៅពេលកើតឧប្បត្តិហេតុ

| លក្ខណៈដី | ភូមិសាស្ត្រ: | អាកាសធាតុ: | ព្រៃស្មៅ: | |
|---|---|---|---|---|
| ទន់ ☐ | រាបស្មើ ☐ | ស្រឡះ ☐ | អត់ស្មៅ ☐ | ព្រៃស្តុក ☐ |
| មធ្យម ☐ | មិនរាបស្មើ☐ | មានកំពក ☐ | ឆេះអស់ ☐ | ព្រៃមធ្យម☐ |
| រឹង ☐ | ជើងភ្នំ ☐ | មានភ្លៀង ☐ | មានស្មៅ ☐ | ព្រៃរបោះ ☐ |
| សើម ☐ | លំហ ☐ | មានខ្យល់☐ | គម្លោតព្រៃ☐ | គ្មានព្រៃ ☐ |
| ស្ងួត ☐ | ស្ងប់ស្ងាត់ ☐ | ត្រជាក់ ☐ | ដំណាំ ☐ | មានថ្ម ☐ |
| | មានកំណត់☐ | មិនក្តៅមិនត្រជាក់ ☐ | ព្រៃ ☐ | ក្តៅ ☐ |

**ផ្នែកទី៦: ក្រុម និង ភារកិច្ចលំអិត**

១៧. ការធ្វើអធិការកិច្ចចុងក្រោយរបស់ក្រុមត្រួតពិនិត្យ ការធានាគុណភាពរបស់ក្រុម

ខែ/ឆ្នាំ........................ /...............................

១៨. លក្ខណៈសម្បត្តិនៃអ្នកបោសសម្អាតមីន ដែលពាក់ព័ន្ធនឹងឧប្បត្តិហេតុ:

ឈ្មោះ............................... មុខងារ..................................... បានចូលរៀនវគ្គ.....................................

១៩. តើក្រុមនេះបាន:

ក- មកដល់ការដ្ឋាននេះរយៈពេលប៉ុន្មាន? ច្រើនថ្ងៃ☐ ច្រើនសប្តាហ៍☐ ច្រើនខែ☐

ខ- អនុវត្តភារកិច្ចនេះរយៈពេលប៉ុន្មាន? ច្រើនថ្ងៃ☐ ច្រើនសប្តាហ៍☐ ច្រើនខែ☐

គ- ធ្វើការប៉ុន្មានម៉ោងក្នុងមួយថ្ងៃ? ច្រើនម៉ោង☐

២០. ប្រភេទម៉ាស៊ីនរាវមីន: លេខសម្គាល់ លក្ខន្តិក: ម៉ាស៊ីនរាវមីន

បញ្ជូនទៅ ដើម្បីត្រួតពិនិត្យផ្នែកបច្ចេកទេស (ទីកន្លែង) (កាលបរិច្ឆេទ)

ប្រើសម្រាប់រាវរកខ្សែមីន? បាទ,ចាស☐ ទេ☐

២១. ប្រភេទឧបករណ៍ដៃ / ប្រភេទដែកចាក់

២២. ឧបករណ៍ការពារខ្លួន: មួកសុវត្ថិភាព☐ របាំងការពារមុខ☐ វ៉ែនតាការពារភ្នែក☐

គ្មាន ☐ ផ្សេងៗ ☐

២៣. យោបល់

**ផ្នែកទី៧: ការព្យាបាល និងការសង្គ្រោះបឋម**

តម្រូវការព្យាបាល បាទ, ចាស☐ ទេ☐ (ឆ្លងទៅទី២៨)

២៥. ការគាំទ្រផ្នែកពេទ្យនៅកន្លែងកើតឧប្បត្តិហេតុ:

ពេទ្យ ☐ សំពៀតសង្គ្រោះបឋម☐ ប្រង់កា ☐

រថយន្តសង្គ្រោះ☐ រថយន្តសុវត្ថិភាព☐ ប្រើវិទ្យុទាក់ទងពេទ្យ☐

២៦. តើបានអនុវត្តតាមក្បួនជម្លៀសជនរងគ្រោះឬទេ ពេលកើតឧប្បត្តិហេតុ?

បាទ, ចាស☐ ទេ☐ (ឆ្លងទៅទី២៨)

២៧. ពេលវេលា និងចម្ងាយ

ក. ពេលវេលាពីកន្លែងកើតឧប្បត្តិហេតុ ទៅកាន់កន្លែងសង្គ្រោះបឋម (នៅការដ្ឋាន)

នាទី ម៉ោង

ខ. ពេលវេលាចំណាយនៅការដ្ឋាន ដើម្បីព្យាបាល នាទី ម៉ោង

គ. ពេលវេលាជម្លៀសជនរងគ្រោះពីការដ្ឋានទៅដល់កន្លែងព្យាបាលនៅទីវាល ឬមន្ទីរពេទ្យក្នុងមូលដ្ឋាន

នាទី ម៉ោង គីឡូម៉ែត្រ

ឃ. ពេលវេលាចំណាយនៅក្នុងមន្ទីរពេទ្យមូលដ្ឋាន ដើម្បីព្យាបាល នាទី ម៉ោង

ង. ពេលវេលាជម្លៀសជនរងគ្រោះពីមន្ទីរពេទ្យមូលដ្ឋាន ទៅកាន់មន្ទីរពេទ្យ ដែលមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីព្យាបាល

នាទី ម៉ោង គីឡូម៉ែត្រ

**ផ្នែកទី៨: នីតិវិធីធ្វើរបាយការណ៍**

-រាយការណ៍ដោយ (ឈ្មោះ) ជូនចំពោះ (ភ្នាក់ងារ)

-តាម(វិធី) នៅ(កាលបរិច្ឆេទ) វេលា(ម៉ោង)

-របាយការណ៍សរសេរ/បកប្រែដោយ: (ហត្ថលេខា)

-ដាក់ឈ្មោះ

-អង្គការ កាលបរិច្ឆេទ

ភ្ជាប់មកជាមួយ:

| | | |
|---|---|---|
| -សេចក្ដីបញ្ជាក់របស់សមាជិកដែលរងរបួស | បាទ, ចាស☐ | ទេ☐ |
| -សេចក្ដីបញ្ជាក់របស់សាក្សី | បាទ, ចាស☐ | ទេ☐ |
| -គំនូរប្លង់នៃកន្លែងកើតឧប្បត្តិហេតុ | បាទ, ចាស☐ | ទេ☐ |
| -រូបថតជនរងគ្រោះ | បាទ, ចាស☐ | ទេ☐ |
| -សន្លឹកទិន្នន័យរងរបួស | បាទ, ចាស☐ | ទេ☐ |
| -រូបថតកន្លែងកើតឧប្បត្តិហេតុ | បាទ, ចាស☐ | ទេ☐ |
| -ច្បាប់ចម្លងផែនទីស្រាវជ្រាវ ១ច្បាប់ | បាទ, ចាស☐ | ទេ☐ |
| -ច្បាប់ចម្លងរបាយការណ៍ឧប្បត្តិហេតុ ១ច្បាប់ | បាទ, ចាស☐ | ទេ☐ |
| -ច្បាប់ចម្លងរបាយការណ៍ពេទ្យ ១ច្បាប់ | បាទ, ចាស☐ | ទេ☐ |
| -ច្បាប់ចម្លងសៀវភៅកំណត់ហេតុរបស់ជនរងគ្រោះ | បាទ, ចាស☐ | ទេ☐ |
| -ព័ត៌មានបច្ចេកទេសលំអិតពីគ្រឿងផ្ទុះ | បាទ, ចាស☐ | ទេ☐ |

១ការេ (១០មម)=          ម៉ែត្រ

**តារាងបញ្ជី**

តំបន់ដាក់សញ្ញាសម្គាល់

- តំបន់ប្រើការបាន
- តំបន់បោសសម្អាតមីនរួច
- តំបន់មិនស្គាល់
- ទីតាំងនៃជនរងគ្រោះ សម្ភារៈ ដែលខូចខាតពេលកើតឧប្បត្តិហេតុ
- **និមិត្តសញ្ញា**
- គ្រឿងផ្ទុះ ✸
- ជនរងគ្រោះទី១ ①
- ជនរងគ្រោះទី២ ②, ③ ។ល។
- សម្ភារៈ/អាគារដែលខូចខាត Ⅱ

## ឧបសម្ព័ន្ធបន្ថែម ក

## គោលការណ៍ណែនាំដើម្បីជ្រើសរើស កម្រិតស៊ើបអង្កេតមួយដែលសមរម្យ

| | ប្រភេទនៃការស៊ើបអង្កេត | | |
|---|---|---|---|
| | គណៈកម្មការ | មន្ត្រីស៊ើបអង្កេតឯករាជ្យ | មន្ត្រីស៊ើបអង្កេតផ្ទៃក្នុង |
| **១.ឧប្បត្តិហេតុដោយការដោះមីន** | | | |
| ក.បណ្តាលមកពីការប្រើប្រាស់ស្តង់ដារ ឬនីតិវិធីដែលអនុម័តរួច | | | |
| ខ.គ្រាប់មីន ឬគ្រាប់មិនទាន់ផ្ទុះនៅសល់ក្នុងពេលដំណើរការដោះមីន | | | |
| គ.ដែលអាចទាក់ទាញការយកចិត្តទុកដាក់ពីព័ត៌ ឬរបាយការណ៍ព័ត៌មាន | | | |
| **២.លទ្ធផលនៃគ្រោះថ្នាក់ដោយសារការដោះមីនដែលបណ្តាលឲ្យ:** | | | |
| ក.អ្នកដោះមីនត្រូវរបួសស្រាល | | | |
| ខ.អ្នកដោះមីនត្រូវរបួសធ្ងន់ | | | |
| គ.ស្លាប់អ្នកដោះមីន | | | |
| ឃ.ត្រូវរបួសអ្នកផ្សេងក្រៅពីអ្នកដោះមីន | | | |
| ង.ស្លាប់អ្នកផ្សេងក្រៅពីអ្នកដោះមីន | | | |
| ច.ខូចខាតសម្ភារៈរបស់អង្គការកំចាត់មីន តិចជាង US$ 5,000.00 | | | |
| ឆ.ខូចខាតសម្ភារៈរបស់អង្គការកំចាត់មីនពី US$ 5,001.00 ទៅ US$50,000 | | | |

| | | | |
|---|---|---|---|
| ជ.ខូចខាតសម្ភារៈដោះមីនលើសពី US$50,000 | | | |
| ឈ.ការខូចខាតទាមទារឲ្យសងជម្ងឺចិត្តពីសាធារណជន | | | |
| **ញ. ហេតុការណ៍បណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរ** | | | |

**កំណត់ចំណាំ ៖**

១. គណៈកម្មការស៊ើបអង្កេត រួមមានសមាជិកថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ឬសមាជិកគ្រប់គ្រងបច្ចេកទេសចំនួន ៣នាក់ ដែលមានលក្ខណៈសម្បត្តិសមរម្យ, សមាជិកមួយរូបមកពីអាជ្ញាធរមីន និងពីររូបទៀត មកពីអង្គការកំចាត់មីនផ្សេងពីគ្នា។

២. អ្នកដែលត្រូវតែងតាំងជាមន្ត្រីស៊ើបអង្កេតរបស់អាជ្ញាធរមីន គប្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

៣. មន្ត្រីស៊ើបអង្កេតផ្ទៃក្នុង ត្រូវជាសមាជិកដែលមានលក្ខណៈសម្បត្តិសមរម្យរបស់អង្គការសកម្មភាពកំចាត់មីន។

# ឧបសម្ព័ន្ធ ខ (ជាពត៌មាន)
# ឧទាហរណ៍ និតីវិធីស៊ើបអង្កេតឧប្បទ្ទវហេតុដោះមីន

| | | |
|---|---|---|
| **ចំណងជើង:** ការស៊ើបអង្កេតឧប្បទ្ទវហេតុដោះមីន | លេខ: | កាលបរិច្ឆេទ: |
| **បំណង:** បង្កើនសុវត្ថិភាព គុណភាពកិច្ចដោះមីនតាមរយៈការប្រមូល វិភាគ និងចែកចាយពត៌មានស្តីពីហេតុការដែលនាំអោយមានឧប្បទ្ទវហេតុដោះមីន។ | អ្នកប្រើប្រាស់: | |
| | អ្នកគ្រប់គ្រង: | |

| ការពិពណ៌នាពីដំណើរការ | ការទទួលខុសត្រូវ | | |
|---|---|---|---|
| | អង្គការកំចាត់មីន | អាជ្ញាធរមីន | មន្ត្រីស៊ើបអង្កេត |
| **របាយការណ៍ឧប្បទ្ទវហេតុដោះមីន:** អនុវត្តនិតីវិធីប្រតិបត្តិការឆ្លើយតបជាបន្ទាន់ និងនិតីវិធីប្រតិបត្តិការ ការពារកន្លែងឧប្បទ្ទវហេតុ ដាក់ជូនរបាយការណ៍ឧប្បទ្ទវហេតុ។ | | | |
| **ការកំណត់បែបផែនស៊ើបអង្កេតដែលត្រូវការ**<br>សូមអានការណែនាំពីការសំរេចចិត្ត ឧបសម្ព័នបន្ថែម ក | | | |
| **សេចក្តីព្រាងឯកសារយោង TOR**<br>សូមអានឧបសម្ព័ន្ធបន្ថែម ខ ដែលបានភ្ជាប់ជាមួយ | | | |
| **តែងតាំងមន្ត្រីស៊ើបអង្កេត TOR:** ផ្តល់ជូនមន្ត្រីស៊ើបអង្កេតនូវសេចក្តីព្រាងឯកសារយោង កូពីជូនអង្គការដែលពាក់ព័ន្ធ ផ្តត់ផ្គង់ផ្នែករដ្ឋបាលតាមតម្រូវការដល់មន្ត្រីស៊ើបអង្កេត ដឹកជញ្ជូន កន្លែងស្នាក់នៅ និងអាហារ។ | | | |
| **មន្ត្រីស៊ើបអង្កេតទទួលបន្ទុកចុះស៊ើបអង្កេត:** អនុលោមតាមសេចក្តីព្រាងឯកសារយោង និង គាំទ្រ ជួយដល់អង្គការ និងនិយោជិកដែលពាក់ព័ន្ធក្នុងឧប្បទ្ទវហេតុ។ | | | |
| តើការស៊ើបអង្កេត និងការធ្វើរបាយការណ៍បញ្ចប់ទាន់ពេលវេលាដែរឬទេ | | | |
| **ដាក់ជូនរបាយការណ៍បណ្តោះអាសន្ន:** ផ្តល់ពត៌មានស្តីពីការវិវឌ្ឍន៍អោយទាន់សភាពការណ៍ ពន្យល់ពីមូលហេតុដែលនាំអោយយឺតយ៉ាវ និងកាលបរិច្ឆេទបញ្ចប់របាយការណ៍។ | | | |
| **ដាក់ជូនរបាយការណ៍ចុងក្រោយ:** ត្រូវធ្វើយ៉ាងណាអោយរបាយការណ៍មានសុក្រឹតភាព ច្បាស់លាស់ សង្ខេប និងពេញលេញ។ | | | |
| **វិភាគរបាយការណ៍ និងផ្សព្វផ្សាយពត៌មានពីលទ្ធផល:** បញ្ជូនព័ត៌មានទៅអង្គការសកម្មភាពកំចាត់មីន និងស្តង់ដាសកម្មភាពកំចាត់មីនអង្គការសហប្រជាជាតិ (បើចាំបាច់) | | | |
| **រៀបចំឯកសាររបាយការណ៍នៅក្នុងទិន្នន័យ:** វិភាគនិន្នាការ ផ្សព្វផ្សាយព័ត៌មាននិន្នាការ បញ្ចូលឧប្បទ្ទវហេតុទៅក្នុងរបៀបវារៈនៃអង្គប្រជុំបច្ចេកទេសការងារលើកក្រោយ។ | | | |




ឯកសារ ដំណើរការ ការទទួលខុសត្រូវទ្វេ ឯកសារច្រើន ការសំរេច អ្នកតភ្ជាប់

## ឧបសម្ព័ន្ធបន្ថែម ខ
## ឯកសារយោង

| | | |
|---|---|---|
| ១. លោក(ឈ្មោះ) | មកពី (អង្គការ) | តាមរយៈនេះ ត្រូវបានតែងតាំងដោយ |
| -(ឈ្មោះ) | នៃអាជ្ញាធរមីន ដើម្បីចុះស៊ើបអង្កេតហេតុការណ៍ជុំវិញ ឧប្បត្តិហេតុមីនដូចខាងក្រោម: | |
| -លេខរៀង: | | |
| -កាលបរិច្ឆេទ/ម៉ោង: | | |
| -ទីកន្លែង: | | |
| -ព័ត៌មានលំអិតរបស់ប្រតិបត្តិករដោះមីន: | | |
| -បុគ្គលិកដែលពាក់ព័ន្ធ: | | |

**២. ការស៊ើបអង្កេត និង របាយការណ៍របស់លោកអ្នក មានដូចខាងក្រោម**:

**ក.** ពេលវេលា ទីកន្លែង របៀប និងមូលហេតុដែលបណ្តាលឲ្យឧប្បត្តិហេតុកើតឡើង

**ខ.** បុព្វហេតុ សភាព និងទំហំនៃការរងរបួស ដែលបណ្តាលមកពីឧប្បត្តិហេតុ

**គ.** បុព្វហេតុ សភាព និងទំហំនៃការខូចខាតចំពោះកម្មវិធីសកម្មភាពកំចាត់មីន ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួន

**ឃ.**កម្រិតនៃការហ្វឹកហ្វឺន និងបទពិសោធន៍របស់អ្នកដែលពាក់ព័ន្ធនៅក្នុងឧប្បត្តិហេតុ

**ង.**រយៈពេលធ្វើការដែលនាំឲ្យមានឧប្បត្តិហេតុ រួមទាំងម៉ោងចាប់ផ្តើមធ្វើការងារនៅថ្ងៃដែលមានឧប្បត្តិហេតុ បើបានឈប់សម្រាកមុនពេលឧប្បត្តិហេតុកើតឡើង (សូមបញ្ជាក់រយៈពេលឈប់សម្រាក)

**ច.** កាលបរិច្ឆេទថ្ងៃឈប់សម្រាកចុងក្រោយបំផុតរបស់អ្នកដោះមីន មុនមានឧប្បត្តិហេតុ

**ឆ.**កាលបរិច្ឆេទពេលព្រឹកនៃថ្ងៃចុះបេសកម្មចុងក្រោយបំផុតរបស់ក្រុម ដែលពាក់ព័ន្ធនឹងឧប្បត្តិហេតុ និងលទ្ធផលនៃបេសកម្មនោះ។

**ជ.**កាលបរិច្ឆេទថ្ងៃហ្វឹកហ្វឺនសារឡើងវិញចុងក្រោយបំផុតសម្រាប់ក្រុម ហើយតើសមាជិកដែលពាក់ព័ន្ធ នៅក្នុងឧប្បត្តិហេតុនោះ បានចូលរួមវគ្គហ្វឹកហ្វឺនសារឡើងវិញដែរឬទេ?

**ឈ.** សម្ភារៈសុវត្ថិភាពដែលពាក់ ឬ ប្រើប្រាស់ដោយអ្នកដែលពាក់ព័ន្ធនៅក្នុងឧប្បត្តិហេតុ តើពាក់ ឬប្រើប្រាស់ត្រឹមត្រូវដែរឬទេ? (សូមថតរូបសម្ភារៈដែលខូចភ្ជាប់មកជាមួយផង)

**៣.** តាមយោបល់របស់លោកអ្នក តើការប្រើប្រាស់សម្ភារៈសុវត្ថិភាពអាចជួយកាត់បន្ថយការរងរបួសដែរឬទេ?

**៤.** តើការព្យាបាល និងការជម្លៀសជនរងគ្រោះសមស្របដែរឬទេ? ឬក៏ធ្វើឲ្យជនរងគ្រោះកាន់តែធ្ងន់ធ្ងរឡើង ឬធ្វើឲ្យស្លាប់?

ឋ. តើមរណភាព របួស ឬការខូចខាតបណ្តាលមកពី:

- ធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមានកិរិយាមិនត្រឹមត្រូវ ដោយការប្រើប្រាស់ថ្នាំញៀន ឬប្រើប្រាស់ឱសថមិនបានត្រឹមត្រូវ។

- ការមិនប្រព្រឹត្តតាមបទបញ្ជា ការណែនាំ ឬបទដ្ឋានសុវត្ថិភាព ឧបករណ៍រំសេវផ្ទុះ ឬសម្ភារៈដែលប្រើប្រាស់ដំណើរការមិនល្អ ។

- កង្វះខាតការហ្វឹកហ្វឺនដល់សមាជិកដែលពាក់ព័ន្ធ

- មានចំណុចខ្សោយនៅក្នុងវិធីបញ្ជា និងត្រួតពិនិត្យ

-លក្ខខ័ណ្ឌអាកាសធាតុ ឬបុព្វហេតុផ្សេងៗ ឌ. ចាត់វិធានការចាំបាច់ជាបន្ទាន់ ដើម្បីទប់ស្កាត់ឧប្បត្តិហេតុកើតឡើងផ្ទួនៗ

ឍ. សុខភាពរបស់អ្នកដោះមីនដែលពាក់ព័ន្ធនៅក្នុងឧប្បត្តិហេតុ

ណ. ការផ្តល់ម្ហូបអាហារ ទឹក និងការការពារពីសមាសភាពរបស់ការដ្ឋាន

ត. ការដូរវេនរបស់អ្នកដោះមីននៅក្នុងមុខសញ្ញា និងម៉ោងនៃការដូរវេនចុងក្រោយមុនឧប្បត្តិហេតុ។

**៣. របាយការណ៍ត្រូវធ្វើការសន្និដ្ឋានដូចខាងក្រោម:**

ក. កត្តាសំខាន់ៗដែលនាំឲ្យមានឧប្បត្តិហេតុ រាប់បញ្ចូលទាំងកង្វះខាតការហ្វឹកហ្វឺន នីតិវិធី សម្ភារៈ ឬការគ្រប់គ្រង។

ខ. តើមានកំហុសឆ្គង ធ្វេសប្រហែស ឬខ្វះការប្រុងប្រយ័ត្នលើផ្នែកមួយរបស់ភ្នាក់ងារកំចាត់មីន បើដូច្នេះ តើសមាជិកណាជាអ្នកទទួលខុសត្រូវ?

**៤. របាយការណ៍ត្រូវធ្វើអនុសាសន៍ដូចខាងក្រោម:**

ក. កែប្រែការហ្វឹកហ្វឺន ឬនីតិវិធី

ខ. ការកែប្រែសម្ភារៈ

គ. ចាត់វិធានការតាមច្បាប់ ឬកែតម្រូវចំពោះបុគ្គល ឬភ្នាក់ងារសកម្មភាពកំចាត់មីន

ឃ. ចាត់វិធានការជាបន្ទាន់ ឬវិធានការយូរអង្វែង ដើម្បីទប់ស្កាត់កុំឲ្យឧប្បត្តិហេតុបែបនេះកើតមាននៅពេលអនាគតទៀត។

**៥. របាយការណ៍របស់លោកអ្នក ត្រូវភ្ជាប់ជាមួយឯកសារដូចខាងក្រោម:**

ក. ថតចម្លងឯកសារយោងទាំងអស់

**ខ.** ថតចម្លងរបាយការណ៍ជនរងគ្រោះ

**គ.** ថតចម្លងរបាយការណ៍ស៊ើបអង្កេតជំហានដំបូង

**ឃ.** សេចក្តីបញ្ជាក់របស់បុគ្គលិកដែលពាក់ព័ន្ធ ឬ សាក្សី

**ង.** ថតរូប និងគូរប្លង់កន្លែងកើតឧប្បត្តិហេតុ (បើកើតនៅក្នុង ឬនៅក្បែរតំបន់ស្រាវជ្រាវ ត្រូវថតចម្លងប្លង់ស្រាវជ្រាវភ្ជាប់មកជាមួយ)

**ច.** ថតរូបបុគ្គលិកដែលរងរបួស និងសម្ភារៈដែលខូចខាត

**៦. របាយការណ៍របស់លោកអ្នក ត្រូវដាក់ជូននៅថ្ងៃទី:**

**៧.** ក្នុងករណីដែលលោកអ្នក មិនអាចដាក់ជូនរបាយការណ៍ដែលពេញលេញតាមកាលបរិច្ឆេទខាងលើបាន លោកអ្នកត្រូវដាក់ជូនរបាយការណ៍បណ្តោះអាសន្ន តាមកាលបរិច្ឆេទខាងលើ និងផ្តល់របាយការណ៍ថ្មី រៀងរាល់ថ្ងៃ រហូតរបាយការណ៍ស៊ើបអង្កេតពេញលេញ ត្រូវបានដាក់ជូនអាជ្ញាធរមីន។

**ហត្ថលេខា**

**កាលបរិច្ឆេទ**